មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

សេចក្តីប្រកាសព័ត៌មាន

# មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា («ម.ស.ម.ក») រៀបចំយុទ្ធនាការបីសប្តាហ៍ដើម្បីចូលរួមប្រារព្ធទិវាអន្តរជាតិដើម្បីបញ្ចប់និទណ្ឌភាពលើឧក្រិដ្ឋកម្មប្រឆាំងអ្នកសារព័ត៌មាន

**រាជធានីភ្នំពេញ ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២២**

ទិវាអន្តរជាតិដើម្បីបញ្ចប់និទណ្ឌភាពលើឧក្រិដ្ឋកម្មប្រឆាំងអ្នកសារព័ត៌មាន ត្រូវបានប្រារព្ធឡើងជារៀងរាល់ឆ្នាំនៅថ្ងៃទី២ ខែវិច្ឆិកា តាំងពីឆ្នាំ២០១៣ មក។ គួរកត់សម្គាល់ថាថ្ងៃពិសេសនេះកាលដំបូងត្រូវបានអង្គការផ្លាស់ប្តូរសេរីភាពបញ្ចេញមតិអន្តរជាតិ («អង្គការអាយហ្វិច») រៀបចំឡើងនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១១ ដើម្បីរំលឹកដល់ការសម្លាប់រង្គាលអ្នកសារព័ត៌មាន និងបុគ្គលិកផ្នែកផ្សព្វផ្សាយចំនួន ៣២ នាក់នៅក្នុងប្រទេសហ្វីលីពីននៅក្នុងឆ្នាំ២០០៩ («ការសម្លាប់រង្គាលនៅអាំពូថាន់»)។ ដោយសារការតស៊ូមតិយ៉ាងទូលំទូលាយដោយអង្គការអាយហ្វិច និងអង្គការដៃគូ បានជំរុញឱ្យសន្និបាតអង្គការសហប្រជាជាតិកំណត់ជាផ្លូវការយកថ្ងៃទី២ ខែវិច្ឆិកា ជាទិវាអន្តរជាតិដើម្បីបញ្ចប់និទណ្ឌភាពលើឧក្រិដ្ឋកម្មប្រឆាំងអ្នកសារព័ត៌មាននៅក្នុងឆ្នាំ២០២១៣។

ទិវានេះគឺជាឱកាសមួយ ដើម្បីជំរុញដល់ការពិភាក្សាអំពីឧក្រិដ្ឋកម្មប្រឆាំងលើអ្នកសារព័ត៌មាន និងអ្នកធ្វើការក្នុងវិស័យប្រព័ន្ធផ្សព្វផ្សាយ ដែលមិនទាន់ត្រូវបានដោះស្រាយ និងដើម្បីសម្តែងនូវការគោរពដល់អ្នកសារព័ត៌មាន ដែលតែងតែប្រថុយប្រថាន ឬបានបាត់បង់អាយុជីវិតក្នុងបុព្វហេតុរាយការណ៍ព័ត៌មានរបស់ខ្លួន។ អ្នកសារព័ត៌មានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់នូវព័ត៌មាន ដែលអាចទុកចិត្តបាន និងត្រឹមត្រូវដល់សាធារណជន។ ដូច្នេះអំពើនិទណ្ឌភាពចំពោះការវាយប្រហារទៅលើអ្នកសារព័ត៌មាន បានបង្កផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ជាពិសេសកម្រិតការយល់ដឹងរបស់សាធារណជន និងការជជែកវែកញែកក្នុងន័យស្ថាបនាលើប្រធានបទ និងបញ្ហាដែលជាប្រយោជន៍សាធារណៈ។ ទិវានេះក៏ជាឱកាស ដើម្បីរម្លឹកដល់រដ្ឋាភិបាលនៅជុំវិញពិភពលោក ត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការលើកកម្ពស់ និងគោរពនូវសេរីភាពសារព័ត៌មាន ព្រមទាំងបញ្ចប់នូវអំពើនិទណ្ឌភាពលើឧក្រិដ្ឋកម្មប្រឆាំងអ្នកសារព័ត៌មានផងដែរ។

ចាប់តាំងពីឆ្នាំ១៩៩៤ យ៉ាងហោចណាស់មានអ្នកសារព័ត៌មានចំនួន ១៥នាក់ ត្រូវបានសម្លាប់នៅក្នុងប្រទេសកម្ពុជា ដោយសារការបំពេញការងាររបស់ខ្លួន។ នៅក្នុងអំឡុងពេលនៃការស្លាប់នេះ ជនរងគ្រោះចំនួន ១២នាក់ស្លាប់ដោយសារពាក់ព័ន្ធនឹងសកម្មភាពរាយការណ៍ព័ត៌មាន ដែលបង្កហានិភ័យដោយផ្ទាល់ដល់បុគ្គលមានអំណាចនៅកម្ពុជា។ មកដល់បច្ចុប្បន្ននេះ ការស៊ើបអង្កេតប្រកបដោយប្រសិទ្ធិភាព ឯករាជ្យភាព និងតម្លាភាព មិនត្រូវបានដំណើរការ ដើម្បីនាំជនល្មើសដែលបានប្រព្រឹត្តិបទឧក្រិដ្ឋមកធ្វើការជំនុំជម្រះ ដែលបណ្តាលឱ្យ

ករណីទាំងអស់នេះមិនត្រូវបានដោះស្រាយ ហើយជនរងគ្រោះមិនទាន់ទទួលបាននូវយុត្តិធម៌ ខណៈដែលជនល្មើសនៅតែបន្តរួចផុតពីការផ្តន្ទាទោសចំពោះអំពើឧក្រិដ្ឋរបស់ខ្លួន។

ដើម្បីប្រារព្ធទិវាអន្តរជាតិដើម្បីបញ្ចប់និទណ្ឌភាពលើឧក្រិដ្ឋកម្មប្រឆាំងអ្នកសារព័ត៌មានឆ្នាំ២០២២ ម.ស.ម.ក នឹងរៀបចំយុទ្ធនាការរយៈពេលបីសប្តាហ៍ចាប់ពីថ្ងៃទី០២ រហូតដល់ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២២ ដោយយោងតាមកាលបរិច្ឆេទទាំងពីរខាងលើ។ តាមរយៈសកម្មភាពជាច្រើនយុទ្ធនាការនេះ ម.ស.ម.ក មានគោលបំណងលើកកម្ពស់ការយល់ដឹងអំពីតួនាទីដ៏សំខាន់របស់អ្នកសារព័ត៌មាននៅក្នុងសង្គមប្រជាធិបតេយ្យ និងអំពើនិទណ្ឌភាពដែលកំពុងបន្តញាំញីក្នុងប្រទេសកម្ពុជា រួមទាំងអំពើឧក្រិដ្ឋកម្មប្រឆាំងអ្នកសារព័ត៌មានផងដែរ។ ម.ស.ម.ក នឹងធ្វើការផ្សព្វផ្សាយជាសាធារណៈ នូវអំពើនិទណ្ឌភាពដែលប្រព្រឹត្តិដោយជនល្មើសនៃឧក្រិដ្ឋកម្មទាំងនោះ និងអំពាវនាវឱ្យបញ្ចប់នូវអំពើនិទណ្ឌភាពដែលជនល្មើសនៅតែបន្តរួចផុតពីការផ្តន្ទាទោស។ សូមចូលរួមជាមួយ ម.ស.ម.ក សម្រាប់ព្រឹត្តិការណ៍ដូចខាងក្រោម៖

- ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២២ ម.ស.ម.ក នឹងចេញផ្សាយសំណួរអនឡាញអំពីសេរីភាពខាងសារព័ត៌មាន និងកិច្ចពិភាក្សាកម្មវិធីវិទ្យុលើប្រធានបទ «និទណ្ឌភាពនៅកម្ពុជា»។
- ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២២ ម.ស.ម.ក នឹងចេញផ្សាយនូវបច្ចុប្បន្នភាពផែនទីបង្ហាញអំពីឃាតកម្មលើអ្នកសារព័ត៌មាន និងផ្សាយឡើងវិញនូវវីដេអូតុក្កតារឿង «**អ្នកបន្តវេន**» ដែលរៀបរាប់ពីកូនប្រុសរបស់អ្នកសារព័ត៌មានម្នាក់ដែលត្រូវបានសម្លាប់ ហើយរូបគេព្យាយាមស្វែងរកយុត្តិធម៌ជូនឪពុករបស់ខ្លួន។
- ថ្ងៃទី០៤ រហូតដល់ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២ ម.ស.ម.ក នឹងចេញផ្សាយនូវសារពីសាធារណៈជនឆ្លើយតបទៅនឹងសំណួរ «តើអ្នកសារព័ត៌មានគួរទទួលបានការការពារដូចម្តេច?» និងវីដេអូប្រវត្តិជនរងគ្រោះពីអំពើនិទណ្ឌភាពចំនួន១២រូប ដែលជាអ្នកសារព័ត៌មាននិងអ្នកធ្វើការផ្នែកប្រព័ន្ធផ្សព្វផ្សាយ។
- ថ្ងៃទី១៦ខែវិច្ឆិកា ឆ្នាំ២០២២ ម.ស.ម.ក និងចេញផ្សាយបណ្ណព័ត៌មានស្តីពីស្ថានភាពនៃសេរីភាពខាងការបញ្ចេញមតិដោយផ្តោតលើអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជាចាប់ពីខែមករាដល់ខែកញ្ញា ឆ្នាំ២០២២។
- នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២២ ម.ស.ម.ក នឹងធ្វើការប្រកាសលទ្ធផលនៃការចូលរួមឆ្លើយសំណួរអនឡាញស្តីពីសេរីភាពខាងសារព័ត៌មាន។
- ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២២ ម.ស.ម.ក នឹងចេញផ្សាយផែនទីបង្ហាញអំពីការរំលោភបំពានសេរីភាពសារព័ត៌មាននៅកម្ពុជា រួមជាមួយនឹងការចេញផ្សាយរបាយការណ៍ប្រចាំឆ្នាំស្តីពី «ស្ថានភាពនៃសេរីភាពខាងការបញ្ចេញមតិ សេរីភាពខាងសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាននៅកម្ពុជា» ចាប់ពីខែកញ្ញា ឆ្នាំ២០២១ ដល់ខែសីហា ឆ្នាំ២០២២ ។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកអ្នកសម្របសម្រួលគម្រោងការលើកកម្ពស់ និងការការពារសេរីភាពខាងការបញ្ចេញមតិ និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ លោក ហួន ផន តាមរយៈអ៊ីម៉ែល

phorn@cchrcambodia.org ឬ ០៧០ ៧៥៧ ៨៨៤ ឬ អ្នកសម្របសម្រួលគម្រោងបង្កើនការគោរពសិទ្ធិនៅកម្ពុជា នៃ ម.ស.ម.ក លោក រស់ សារ៉ាត់ តាមរយៈអ៊ីម៉ែល rossarath@cchrcambodia.org ឬ ០១៧ ៨៨៦ ៦៩៥៕

**ចប់**

**បណ្ណាធិការៈ**

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា "ម.ស.ម.ក" បានបង្កើតឡើងក្នុង ខែវិច្ឆិកា ឆ្នាំ២០០២ គឺជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ពន្ធ ដែលធ្វើការលើកកម្ពស់ និងការពារលិទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។

ម.ស.ម.ក គឺជាសមាជិកនៃ អង្គការផ្លាស់ប្តូរសេរីភាពបញ្ចេញមតិអន្តរជាតិ (IFEX) ដែលជាបណ្តាញសកលសម្រាប់សេរីភាពនៃការបញ្ចេញមតិ និង CIVICUS ៖ សម្ព័ន្ធពិភពលោកសម្រាប់ការចូលរួមរបស់ពលរដ្ឋ។ ម.ស.ម.ក ក៏ជាសមាជិកនៃអង្គការប្រឆាំងទារុណកម្មពិភពលោក (MOCT SOS-Torture Network) និង ជាសមាជិក OECD Watch ។

គេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជា www.sithi.org ទទួលបានពានរង្វាន់ពីមូលនិធិនៃការបង្កើតសារព័ត៌មានថ្មីប្រចាំឆ្នាំ២០១១ ស្ថិតក្នុងប្រភេទ "សិទ្ធិ និង សេរីភាព" និងទទួលពានរង្វាន់ ទំនាក់ទំនងសម្រាប់ការផ្លាស់ប្តូរសង្គម មកពីមជ្ឈមណ្ឌលសម្រាប់ទំនាក់ទំនង និងផ្លាស់ប្តូរសង្គម នៅសាកលវិទ្យាល័យឃ្វីនឡែនក្នុងទីក្រុងប្រ៊ីសប៊ែន (Brisbane) នៃប្រទេសអូស្ត្រាលី។